ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៤៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពី ការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៤៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម

## សម្រេច

**មាត្រាមួយ .-**

មាត្រា ៣ និងមាត្រា១០ នៃអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ត្រូវបានធ្វើការកែសម្រួលដូចខាងក្រោម៖

**មាត្រា ៣ ថ្មី .-**

គ.ប.ក.គ មានសមាសភាពដូចតទៅ៖

| | | |
|---|---|---|
| ១- | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ១ រូប | ប្រធាន |
| ២- | រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ១ រូប | អនុប្រធាន |
| ៣- | រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ១ រូប | អនុប្រធាន |
| ៤- | រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការក្រសួងសុខាភិបាល ១ រូប | អនុប្រធាន |
| ៥- | អគ្គលេខាធិការក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ | អនុប្រធាន |
| ៦- | អគ្គលេខាធិការក្រុមប្រឹក្សាជាតិគាំពារសង្គម | អនុប្រធានប្រចាំការ |
| ៧- | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១ រូប | សមាជិក |
| ៨- | តំណាងក្រសួងមហាផ្ទៃ ១ រូប | សមាជិក |
| ៩- | តំណាងក្រសួងការពារជាតិ ១ រូប | សមាជិក |
| ១០- | តំណាងក្រសួងផែនការ ១ រូប | សមាជិក |
| ១១- | តំណាងក្រសួងយុត្តិធម៌ ១ រូប | សមាជិក |
| ១២- | តំណាងក្រសួងកិច្ចការនារី ១ រូប | សមាជិក |
| ១៣- | តំណាងក្រសួងអប់រំ យុវជន និងកីឡា ១ រូប | សមាជិក |
| ១៤- | តំណាងក្រសួងមុខងារសាធារណៈ ១ រូប | សមាជិក |
| ១៥- | តំណាងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ១ រូប | សមាជិក |
| ១៦- | អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ១៧- | អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៨- | អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក។ |

គ.ប.ក.គ អាចមានសមាសភាពបន្ថែមតាមការចាំបាច់។ សមាសភាពជាក់ស្តែងនៃ គ.ប.ក.គ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា ១០ ថ្មី . -**

អ.ក.គ. មាននាយកដ្ឋានក្រោមឱវាទចំនួន ៥ ដូចខាងក្រោម៖

១. នាយកដ្ឋានជំនួយសង្គម មានមុខងារ និងភារកិច្ចជួយ អ.ក.គ. លើការងារជំនួយសង្គម

២. នាយកដ្ឋានសន្តិសុខសង្គម មានមុខងារ និងភារកិច្ចជួយ អ.ក.គ. លើការងារសន្តិសុខសង្គម

៣. នាយកដ្ឋានត្រួតពិនិត្យ មានមុខងារ និងភារកិច្ចជួយ អ.ក.គ. លើការងារត្រួតពិនិត្យប្រតិបត្តិករសន្តិសុខសង្គម

៤. នាយកដ្ឋានផ្សះផ្សាវិវាទ និងការពារអ្នកទទួលផល មានមុខងារ និងភារកិច្ចជួយ អ.ក.គ. លើការងារផ្សះផ្សាវិវាទ និងការពារអ្នកទទួលផល

៥. នាយកដ្ឋានកិច្ចការទូទៅ មានមុខងារ និងភារកិច្ចជួយ អ.ក.គ. លើការងារទូទៅ។

នាយកដ្ឋាននីមួយនៃ អ.ក.គ. ដឹកនាំដោយប្រធាន ១ រូប និងមានអនុប្រធានមួយចំនួន អនុលោមតាមបទប្បញ្ញត្តិជាធរមាន

មុខងារ និងភារកិច្ចលម្អិតនៃនាយកដ្ឋានក្រោមឱវាទ អ.ក.គ. និង អង្គការលេខរបស់ អ.ក.គ. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម។

**មាត្រាពីរ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**តារាងឧបសម្ព័ន្ធ៖**

**កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩**

| ខែ | ចំនួនគ្រួសារបានកំណត់អត្តសញ្ញាណ | ថវិកាដែលបានគ្រោង (រៀល) | ចំនួនគ្រួសារបានទទួលប្រាក់ឧបត្ថម្ភ | ចំណាយបើកផ្តល់ (រៀល) | ភាគរយនៃការអនុវត្តជាក់ស្តែង |
|---|---|---|---|---|---|
| **ខែទី១** | 562,686 | 100,886,303,200 | 530,838 | 94,551,876,000 | 94% |
| **ខែទី២** | 613,564 | 110,822,872,800 | 598,512 | 106,874,256,000 | 98% |
| **ខែទី៣** | 669,580 | 121,037,304,000 | 644,665 | 115,246,140,000 | 96% |
| **ខែទី៤** | 689,973 | 125,172,687,600 | 661,684 | 118,317,120,000 | 96% |
| **ខែទី៥** | 697,577 | 126,501,878,200 | 674,146 | 120,512,404,000 | 97% |
| **ខែទី៦** | 704,144 | 127,708,098,400 | 681,999 | 122,014,940,000 | 97% |
| **ខែទី៧** | 708,173 | 128,455,001,200 | 685,447 | 122,642,900,000 | 97% |
| **ខែទី៨** | 710,929 | 128,943,304,400 | 688,539 | 122,156,208,000 | 97% |
| **ខែទី៩** | 714,500 | 129,573,889,600 | 692,092 | 122,677,392,000 | 97% |
| **ខែទី១០** | 716,184 | 129,886,542,400 | 693,333 | 122,926,148,000 | 96% |
| **ខែទី១១** | 717,820 | 130,173,921,600 | 693,333 | 123,324,472,000 | 98% |
| **ខែទី១២** | 662,767 | 118,196,032,400 | 652,484 | 115,824,944,000 | 98% |
| **ខែទី១៣** | 665,292 | 118,624,710,400 | 658,857 | 117,261,296,000 | 98% |
| សរុប | - | **1,595,982,546,200** | - | **1,524,330,096,000** | - |

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ១៤៣អនក.បក.ចុះថ្ងៃទី..១៩....ខែ.សីហា.....ឆ្នាំ២០២១

**អង្គការលេខរបស់**
**អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម**

